ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៤៧៦ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធប្រជុំអង្គ មកជាសាលាបឋមសិក្សាពេញលក្ខណៈ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ០១.០៣.បឋជក.របស់នាយកសាលាបឋមសិក្សាជើងកើប ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំ យុវជននិង កីឡា ខេត កណ្តាល ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

**សំរេច**

<u>**ប្រការ១:**</u> ផ្តាច់សាលាឧបសម្ព័ន្ធ **ប្រជុំអង្គ** ពីសាលាបឋមសិក្សា **ជើងកើប** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ដែលមានទីតាំងស្ថិតនៅ ឃុំ **ជើងកើប** ស្រុក **កណ្តាលស្ទឹង** ខេត្ត **កណ្តាល** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

<u>**ប្រការ២:**</u> សាលាបឋមសិក្សា **ប្រជុំអង្គ** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

<u>**ប្រការ៣:**</u> នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

<u>**ប្រការ៤:**</u> បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

<u>**ប្រការ៥:**</u> អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជននិង កីឡាស្រុក **កណ្តាលស្ទឹង** នាយកសាលាបឋមសិក្សា **ជើងកើប** នាយកសាលាបឋមសិក្សា **ប្រជុំអង្គ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៥ ខែ ៧ ឆ្នាំ ២០០៣

ក.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

<u>**កន្លែងទទួល**</u>

-ទិស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កណ្តាល

-"<u>**ដើម្បីជូនជ្រាបជាពត៌មាន**</u>"

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ នា.បស